ក្រុមយុវនារី

ប្រារព្ធខួប ១៥០ ឆ្នាំ

ដោយ អាម៉ានដា ដាន់
ទស្សនាវដ្ដីសាសនាចក្រ

អង្គការយុវនារីឈានចូលដល់ ១៥០ ឆ្នាំហើយនៅឆ្នាំនេះ ហើយវាដល់ពេលប្រារព្ធអបអរហើយ ! សូមក្រឡេកមើលការពិតទាំងនេះអំពីរបៀបដែលអង្គការនេះបានវិវត្តតាំងពីឆ្នាំ ១៨៧០ រហូតដល់សព្វថ្ងៃនេះ អ្វីដែលយុវវ័យដូចជាប្អូនៗកំពុងតែធ្វើដើម្បីចូលរួមនៅក្នុងក្រុមយុវនារីឥឡូវនេះ និងរបៀបដែលប្អូនៗអាចត្រូវបានបំផុសដោយពួកយុវនារីនៅក្នុងប្រវត្តិសាស្ត្រ ដែលបានបង្ហាញភាពក្លាហាន និងសេចក្ដីជំនឿ ។

ឆ្នាំ ១៨៧០-១៩២០



ឈ្មោះ ៖ ស្ថាប័នស្ត្រីវ័យក្មេងនៃសមាគមន៍សហការកាត់បន្ថយរបស់ស្ត្រី ត្រូវបានបង្កើតឡើងជាផ្លូវការ នៅថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៨៧០ ក្រោមការដឹកនាំរបស់ព្រិកហាំ យ៉ង់ ។[1] ឈ្មោះនោះត្រូវបានផ្លាស់ប្ដូរទៅជា សមាគមន៍កែលម្អទៅវិញទៅមក សម្រាប់ស្ត្រីវ័យក្មេង នៅក្នុងឆ្នាំ ១៨៧៧ ។[2]

អង្គការ និងថ្នាក់ទាំងឡាយ ៖ កម្មវិធីនារីបីហៃ ត្រូវបានបង្កើតឡើងជាកម្មវិធីរដូវក្ដៅសម្រាប់ក្មេងស្រីអាយុ ១៤ ឆ្នាំ និងច្រើនជាងនោះ ។

ការអភិវឌ្ឍ និងការទទួលស្គាល់ ៖ សៀវភៅក្បួនខ្នាតបីហៃត្រូវបានបោះពុម្ពនៅក្នុងឆ្នាំ ១៩១៥ ដោយមានគូសបញ្ជាក់នូវ « ផ្នែក » ចំនួនប្រាំពីរនៃការអភិវឌ្ឍផ្ទាល់ខ្លួន ៖ សាសនា គេហដ្ឋាន សុខភាព សិល្បៈក្នុងស្រុក សកម្មភាពក្រៅផ្ទះ ជំនួញ និងសេវាកម្មសាធារណៈ ។[3]

ទស្សនាវដ្ដី និងកំណត់ហេតុ ៖ ច្បាប់ដំបូងនៃ *កំណត់ហេតុយុវនារី*ត្រូវបានបោះពុម្ពនៅក្នុងឆ្នាំ ១៨៨៩ ។[4] សមាគមន៍កែលម្អទៅវិញទៅមកជាច្រើនក្នុងតំបន់ (ឬ ស.ក.ទ.) ផលិតសារព័ត៌មានដែលសរសេរដោយដៃ និងមានតែមួយ ឬពីរច្បាប់ប៉ុណ្ណោះដើម្បីឲ្យក្មេងស្រីទាំងឡាយចែកគ្នាអាន ។

ឆ្នាំ ១៩២០-១៩៧០

រូបថតយុវនារីពាក់មេដាយការអភិវឌ្ឍខ្លួន ដោយ អាលីស្សា ស័រវ៉ា
រូបថតរបស់យុវនារី ទទួលបានសិទ្ធិអនុញ្ញាតពីបណ្ណាល័យប្រវត្តិសាស្ត្រសាសនាចក្រ



ឈ្មោះ ៖ សមាគមន៍កែលម្អទៅវិញទៅមកសម្រាប់ស្ត្រីវ័យក្មេង ផ្លាស់ប្ដូរទៅជា សមាគមន៍កែលម្អទៅវិញទៅមកសម្រាប់យុវនារី នៅក្នុងឆ្នាំ ១៩៣៤ ។[5]

អង្គការ និងថ្នាក់ទាំងឡាយ ៖ មានថ្នាក់ចំនួនពីរ គឺ នារីបីហៃ សម្រាប់ក្មេងស្រីដែលក្មេងៗជាង និង គ្លីននែរ សម្រាប់ក្មេងស្រីដែលមានអាយុច្រើនជាង ។ អាយុដើម្បីចូលក្នុងកម្មវិធីនោះផ្លាស់ប្ដូរពី ១៤ ទៅ ១២ ឆ្នាំ ។ នៅក្នុងឆ្នាំ ១៩៥០ ថ្នាក់ម៉ៃម៉េតត្រូវបានណែនាំឲ្យស្គាល់ ។

ការអភិវឌ្ឍ និងការទទួលស្គាល់ ៖ ការទទួលស្គាល់គ្លីននែរមាស កំណត់ពីការសម្រេចបានខ្ពស់បំផុតដែលយុវនារីអាចទទួលបាននៅក្នុងកម្មវិធីនោះ ។

ទស្សនាវដ្ដី និងកំណត់ហេតុ ៖ *កំណត់ហេតុយុវនារី* បញ្ចូលជាមួយនឹងទស្សនាវដ្ដី *Improvement Era* សម្រាប់យុវវ័យទាំងអស់ នៅក្នុងឆ្នាំ ១៩២៩ ។[6]

ឆ្នាំ ១៩៧០-២០១៩



ឈ្មោះ ៖ សមាគមន៍កែលម្អទៅវិញទៅមកសម្រាប់យុវនារី ផ្លាស់ប្ដូរទៅជា អង្គការយុវនារី នៅក្នុងឆ្នាំ ១៩៧៤ ។[7]

អង្គការ និងថ្នាក់ទាំងឡាយ ៖ មកដល់ត្រឹមឆ្នាំ ១៩៧២ អង្គការយុវនារីមានបីថ្នាក់គឺ ៖ បីហៃ (អាយុ ១២–១៣ ឆ្នាំ) ម៉ៃម៉េត (អាយុ ១៤–១៥ ឆ្នាំ) និងឡូរ៉េល (អាយុ ១៦–១៧ ឆ្នាំ) ។ ចាប់ផ្ដើមក្នុងឆ្នាំ ២០១៩ យុវនារីចូលរួមក្នុងថ្នាក់បីហៃនៅខែមករានៃឆ្នាំដែលពួកគេឈានចូលអាយុ ១២ ឆ្នាំ ។

ការអភិវឌ្ឍ និងការទទួលស្គាល់ ៖ កម្មវិធីការអភិវឌ្ឍខ្លួន និងមេដាយត្រូវបានណែនាំឲ្យស្គាល់នៅក្នុងឆ្នាំ ១៩៧៧ ។ យុវនារីផ្ដល់តម្លៃដល់ សេចក្ដីជំនឿ និស្ស័យនៃព្រះ គុណសម្បត្តិផ្ទាល់ខ្លួន ចំណេះវិជ្ជា ការជ្រើសរើស និងការទទួលខុសត្រូវ កិច្ចការល្អ និងសេចក្ដីទៀងត្រង់ ត្រូវបានបន្ថែមនៅក្នុងឆ្នាំ ១៩៨៧ ។[8] គុណធម៌ត្រូវបានបន្ថែមនៅក្នុងឆ្នាំ ២០០៨ ។[9]

ទស្សនាវដ្ដី និងកំណត់ហេតុ ៖ ទស្សនាវដ្ដី *New Era* សម្រាប់យុវវ័យបានចាប់ផ្ដើមការបោះពុម្ពជាភាសាអង់គ្លេសនៅក្នុងឆ្នាំ ១៩៧១ ហើយ *លីអាហូណា* ផ្ដល់នូវអត្ថបទទាំងឡាយសម្រាប់យុវវ័យនៅក្នុងភាសាជាច្រើន ។[10]